ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីវិនិយោគសាធារណៈ

# ៣ឆ្នាំរំកិល

# ២០១៤ - ២០១៦

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ

នាថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៣

រៀបចំដោយក្រសួងផែនការ

# បុព្វកថា

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន* នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍បញ្ជាក់ឱ្យដឹងថា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) បច្ចុប្បន្នកម្ម ២០០៩-២០១៣** គឺជាឯកសារសំខាន់មួយសម្រាប់គ្រប់គ្រងរាល់ការវិនិយោគ អភិវឌ្ឍន៍លើវិស័យសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៩៦ ក្រសួងផែនការជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ **កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល** ជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់តម្រូវការជំនួយវិនិយោគជាទុន និងជំនួយបច្ចេកទេសក្នុងការអនុវត្តផ.**យ.អ.ជ.**។ ក្នុងការរៀបចំ**ក.វ.ស. ៣ឆ្នាំរំកិល** ឆ្នាំ២០០៦-២០០៨ ឆ្នាំ២០០៧-២០០៩ ឆ្នាំ២០០៨-២០១០ ឆ្នាំ២០០៩-២០១១ ឆ្នាំ២០១០-២០១២ ឆ្នាំ២០១១-២០១៣ ឆ្នាំ២០១២-២០១៤ ឆ្នាំ២០១៣-២០១៥ និងឆ្នាំ២០១៤-២០១៦ គឺការវិភាជថវិកាបានឆ្លើយតបទៅនឹងការវិភាជដែលមានចែងនៅក្នុង**ផ.យ.អ.ជ. ២០០៦-២០១០** និង**ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣**។

ក្រសួងផែនការបានបន្តធ្វើការកែសម្រួលបន្ថែមទៀតលើដំណើរការរៀបចំ**ក.វ.ស. ៣ឆ្នាំរំកិល ២០១៤ -២០១៦** ដោយបានរៀបចំការធ្វើការពិភាក្សាដោយផ្ទាល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្តាក្រសួង ស្ថាប័ននីមួយៗ ដើម្បីធានាថាការធ្វើទិន្នន័យគម្រោងរបស់បណ្តាក្រសួង ស្ថាប័នទាំងអស់សម្រាប់រៀបចំ**ក.វ.ស. ៣ឆ្នាំរំកិល ២០១៤-២០១៦** បានឆ្លើយតបទៅនឹងអាទិភាពរបស់**ផ.យ.អ.ជ.**។

**ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣** បានបញ្ជាក់យ៉ាងច្បាស់លាស់ពីទំនាក់ទំនងនៃ **ផ.យ.អ.ជ. ក.វ.ស. ៣ឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ**។ បច្ចុប្បន្នថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងសម្របសម្រួលនិងប្រឹងប្រែងទាំងអស់គ្នា ដើម្បីធានាបាននូវសុខដុមនីយកម្មការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងគ្រប់គ្រងហិរញ្ញប្បទាន។

ខ្ញុំមានសេចក្តីរីករាយ និងសូមធ្វើការបង្ហាញនូវ**ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦** សម្រាប់ជាព័ត៌មាន និងការប្រើប្រាស់របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដៃគូអភិវឌ្ឍ។ សូមឆ្លៀតយកឱកាស នេះដើម្បីបញ្ជាក់ឡើងវិញម្តងទៀតនិងជំរុញដល់ដៃគូអភិវឌ្ឍដែលផ្តល់ការជួយឧបត្ថម្ភគាំទ្រដល់ប្រទេសកម្ពុជា ត្រូវមានមូលដ្ឋានពិនិត្យលើគម្រោង ***សម្រាប់អនុវត្តផ.យ.អ.ជ.*** នៃបញ្ជីគម្រោង**ក.វ.ស. ៣ឆ្នាំរំកិល ២០១៤-២០១៦** ដែលនឹងនាំយើងឈានទៅសម្រេចបាននូវគោលបំណងនិងអាទិភាព ដែលមានចែងនៅក្នុង**ផ.យ.អ.ជ.** និងដើម្បីកាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

*ក្រសួងផែនការ*

*ខែ ឆ្នាំ២០១៣*

***ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ***

**ឆាយ ថន**

# សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា





# មាតិកា

ទំព័រ

បុព្វកថា ... i
សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ... ii
មាតិកា ... iii

ជំពូកទី១-សេចក្តីផ្តើម
ដំណើរការសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ ... ១
វិធីសាស្រ្តសម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៤-២០១៦ ... ២

ជំពូកទី២-ទស្សនវិស័យសេដ្ឋកិច្ចឆ្នាំ២០១៤-២០១៦ ... ៦
ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប ២០១៤-២០១៦ ... ៦
អត្រាកំណើនផ.ស.ស.ពិត(ថ្លៃថេរឆ្នាំ២០០០)ដោយសកម្មភាពសេដ្ឋកិច្ច...៧
ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចនូវកំណើនផ.ស.ស.ដែលបានគ្រោងទុក ... ៩
ចំណូលនិងចំណាយថវិកា២០១៤-២០១៦... ១២
ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១៤-២០១៦ ... ១៣

ជំពូកទី៣-កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៤-២០១៦ ... ១៧
ជំពូកទី៤-សេចក្តីសន្និដ្ឋាន ... ៣៨

# បញ្ជីតារាង

តារាងទី១-ការព្យាករពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ... ៧
តារាងទី២-អត្រាកំណើនផ.ស.ស.(ថ្លៃថេរឆ្នាំ២០០០)ដោយសកម្មភាពសេដ្ឋកិច្ច ... ៨
តារាងទី៣-ការវិនិយោគមូលធនចាំបាច់ដើម្បីសម្រេចបានកំណើនផ.ស.ស.ដែលបានគ្រោងទុកនិងធនធានដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់ ... ១០
តារាងទី៤-វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗ ដើម្បីសម្រេចបាននូវគោលដៅនៃកំណើន ផ.ស.ស. ... ១១

តារាងទី៥-ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១៤-២០១៦ .......... ១៤

តារាងទី៦-ការវិភាជតាមវិស័យនិងអនុវិស័យសម្រាប់គម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដោយមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យ ចែងនៅក្នុងផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ .......... ១៥

តារាងទី៧-ការវិភាជតាមវិស័យនិងអនុវិស័យ សម្រាប់គម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុងផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ និង ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦ .... ១៧

តារាងទី៨-សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ដែលក្រសួង ស្ថាប័នស្នើសុំសម្រាប់ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦ .......... ២០

តារាងទី៩-គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. បែងចែកតាមវិស័យអាទិភាពនៃផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ ដែលក្រសួង ស្ថាប័នស្នើសុំ ....... ២១

តារាងទី១០-បរិមាណខុសគ្នានៃការវិភាជតាមអនុវិស័យ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ និងការស្នើសុំដោយក្រសួង ស្ថាប័ន .......... ៣៣

តារាងទី១១-សេចក្តីសង្ខេបការវិភាជតាមវិស័យក្នុងផ.យ.អ.ជ. បច្ចុប្បន្នកម្ម និងចំណាយប៉ាន់ស្មានតាមក្រសួង ស្ថាប័ន ..........៣៤

តារាងទី១២-បញ្ជីគម្រោងបែងចែកតាមក្រសួង ស្ថាប័ន .......... ៣៩

តារាងទី១៣-បញ្ជីគម្រោងតាមវិស័យ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម និងក្រសួង ស្ថាប័ន ..........១០២

# ជំពូកទី១
## សេចក្តីផ្តើម

១-គោលបំណងសំខាន់នៃ*កម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.) ៣ឆ្នាំរំកិល២០១៤-២០១៦* គឺធ្វើការបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយមានចែងនៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងក្នុង*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.)បច្ចុប្បន្នកម្ម២០០៩-២០១៣*។ *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១០ ត្រូវបានរៀបចំឡើងដោយមានមូលដ្ឋានពីធាតុចូលរបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា។

២- *ក.វ.ស. ៣ឆ្នាំរំកិល* បានដាក់បញ្ចូលគ្នា*គម្រោងកំពុងដំណើរការ*ដែលការអនុវត្តគម្រោង កំពុងបន្តនៅក្នុងដំណាក់កាល ក.វ.ស. និង*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ជាគម្រោងស្នើសុំថ្មីដែលត្រូវនឹងការអនុវត្តក្នុងដំណាក់កាល ក.វ.ស.។

ប្រភពទិន្នន័យសម្រាប់រៀបចំក.វ.ស. រួមមាន៖

(១) ព័ត៌មានស្តីពី*គម្រោងកំពុងដំណើរការ* ក្នុងនោះគម្រោងកំពុងដំណើរការក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវបានផ្តល់ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងពិនិត្យកែសម្រួលដោយក្រសួង ស្ថាប័នអនុវត្តគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា។ និង

(២) ព័ត៌មានស្តីពី *គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ដែលក្រសួងផែនការបានទទួលពីក្រសួង ស្ថាប័ន ទាំងអស់សម្រាប់រៀបចំ*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦*។

### ក. ដំណើរការនៃការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ

៣- នៅពាក់កណ្តាលឆ្នាំ២០០៩ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបង្កើត*ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ* ដើម្បីពង្រឹងការងារសុខដុមនីយកម្ម ការងារផែនការ និងការអនុវត្តជាក់ស្តែង ដែលជាគោលដៅសំខាន់នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២។

៤-បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងធ្វើការពង្រឹងសមត្ថភាពស្ថាប័នដើម្បីភ្ជាប់ទំនាក់ទំនងនៃដំណើរការ៖

(១)កំណត់តម្រូវការជាអាទិភាពសម្រាប់វិនិយោគតាមរយៈកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ដែលរៀបចំឡើងដោយក្រសួងផែនការ

(២) រៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
(៣) រៀបចំទិន្នន័យនៃគម្រោងវិនិយោគមូលធន ដែលកំពុងដំណើរការរបស់នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង
(៤) រៀបចំទិន្នន័យនៃគម្រោងកំពុងដំណើរការនិងការវិភាជធនធានរបស់ដៃគូអភិវឌ្ឍនានា ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៥- ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការនេះដឹកនាំដោយក្រសួងផែនការ និងមានសមាជិកមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមការងារបានរៀបចំកិច្ចប្រជុំជាច្រើនដងដើម្បីពិភាក្សានិងកំណត់ទិសដៅការងាររបស់ខ្លួន។ បច្ចុប្បន្ននេះ មានក្របខ័ណ្ឌការងាររួមមួយសម្រាប់ការតាមដានត្រួតពិនិត្យការងាររបស់ក្រុមការងារ ត្រូវបានកំណត់ជាសូចនាករសម្រាប់ការតាមដានរួមគ្នា(JMIs)សម្រាប់សកម្មភាពនេះ។ តាមរយៈសូចនាករសម្រាប់ការតាមដានរួមគ្នា ពេលនេះក្រុមការងារកំពុងដំណើរការធ្វើការវិភាគស្ថានភាពលើការងាររបស់ខ្លួនដែលនឹងត្រូវសម្រេចដោយ*គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* និងរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តក្នុងពេលអនាគតដ៏ខ្លី។

## ខ. វិធីសាស្ត្រសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៤-២០១៦

៦- សម្រាប់ការរៀបចំ*កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៤-២០១៦* ក្រសួងផែនការបាននិងកំពុងបន្តធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីឈានទៅសម្រេចបាននូវ*សុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ និងដើម្បីពង្រឹងយន្តការស្ថាប័ននៃការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព*។

៧- វិធីសាស្ត្រសម្រាប់ការរៀបចំ*កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៤-២០១៦* ត្រូវបានអនុវត្តដូចការរៀបចំ*កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៣-២០១៥*។ ដោយវិធីសាស្ត្រថ្មីនេះ រួមមាន *គម្រោងកំពុងដំណើរការ* គឺជាគម្រោងដែលកំពុងត្រូវបានអនុវត្តឬមានកិច្ចសហការនិងការសម្របសម្រួលជាមួយស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយការអនុវត្តគម្រោងទាំងនោះនឹងត្រូវបន្តនៅក្នុងអំឡុងពេលនៃក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦ និង*គម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ឬគម្រោងថ្មី* ដែលនឹងត្រូវអនុវត្តក្នុងអំឡុងពេលនៃ ក.វ.ស. ៣ឆ្នាំរំកិល ២០១៤-២០១៦។ គម្រោងកំពុងដំណើរការ គឺត្រូវបានដាក់បញ្ចូលនូវគម្រោងដែលកំពុងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិលនានា ដោយសហការជាមួយក្រសួង ស្ថាប័នតាមវិស័យពាក់ព័ន្ធ។ ព័ត៌មានសម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦ ត្រូវបានធ្វើការកែលម្អតាមរយៈកម្រងបញ្ជីសំណួរថ្មីដែលបានចែកចេញជាពីរផ្នែក។ ផ្នែកទី១ គឺការប្រមូលព័ត៌

មានស្តីពី*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* និង ផ្នែកទី២ គឺការប្រមូលព័ត៌មានស្តីពី*គម្រោងកំពុងដំណើរការ*ដែលបញ្ជីសំណួរ ក.វ.ស. ៣ឆ្នាំរំកិលថ្មីមានបង្ហាញក្នុងឧបសម្ព័ន្ធ១។

៨- សម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦ និងតាមសំណើរបស់ក្រសួងផែនការ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានផ្ញើមកក្រសួងផែនការនូវព័ត៌មានស្តីពី*ការចំ-ណាយជំនួយអភិវឌ្ឍផ្លូវការទៅតាមគម្រោងនិងក្រសួង ស្ថាប័នដែលរាយការណ៍ដោយដៃគូអភិវឌ្ឍជារៀងរាល់ឆ្នាំ*។ គម្រោងកំពុងដំណើរការទាំងអស់ដែលរាយការណ៍ដោយដៃគូអភិវឌ្ឍគឺជាបណ្តាគម្រោងដែលកំពុងអនុវត្តដោយៈ (១) ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល (២) ដៃគូអភិវឌ្ឍ និង(៣) អង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិល ដោយមានការគាំទ្រផ្តល់ថវិកាពីដៃគូអភិវឌ្ឍ។

៩- ប្រភពទិន្នន័យសំខាន់សម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦ គឺក្រសួងផែនការបានទទួលពីគ្រប់ក្រសួង ស្ថាប័ន។ ក្រសួងផែនការបានទទួលស្គាល់ថាក្រសួង ស្ថាប័នផ្តល់តែព័ត៌មានសម្រាប់*គម្រោងកំពុងដំណើរការ* ដែលកំពុងអនុវត្តដោយមានឬពុំមានកិច្ចសហការជាមួយក្រសួង ស្ថាប័នរបស់ខ្លួននីមួយៗ។ តាមរយៈការអនុវត្តជាក់ស្តែង យើងទទួលស្គាល់ថាទិន្នន័យស្តីពីគម្រោងកំពុងដំណើរការដែលក្រសួង ស្ថាប័នផ្ញើមកក្រសួងផែនការ មានដាក់បញ្ចូលនូវគម្រោងកំពុងដំណើរការមួយចំនួន ដែលដៃគូអភិវឌ្ឍបានរាយការណ៍ជូនគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា។ ប៉ុន្តែដើម្បីធានាបាននូវការកត់ត្រាច្បាស់លាស់នូវចំនួនគម្រោងកំពុងដំណើរការដែលកំពុងអនុវត្តដោយមានឬពុំមានកិច្ចសហការជាមួយក្រសួង ស្ថាប័ននីមួយៗ និងដើម្បីជួយសម្រួលដល់ការរៀបចំទិន្នន័យគម្រោងកំពុងដំណើរការរបស់ក្រសួង ស្ថាប័ន ក្រសួងផែនការបានផ្ញើបញ្ជីគម្រោងកំពុងដំណើរការដែលបានទទួលពីគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាទៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីពិនិត្យនិងដាក់បញ្ចូលសម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦។

១០- ចំពោះ*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(គម្រោងថ្មី)* ដែលនឹងត្រូវអនុវត្តក្នុងអំឡុងឆ្នាំ២០១៤-២០១៦ ក្រសួងផែនការបានផ្តល់សេចក្តីណែនាំនិងពន្យល់ដោយផ្ទាល់ដល់គ្រប់ក្រសួង ស្ថាប័ន បន្ថែមពីលើការពន្យល់តាមរយៈសិក្ខាសាលាជាតិនាពេលកន្លងមក ដើម្បីធានាថាក្នុងការស្នើសុំ *គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ក្រសួង ស្ថាប័នទាំងអស់បានៈ

(១) គិតច្បាស់លាស់ពីសារៈសំខាន់នៃគម្រោងទាំងនោះ ក្នុងការគាំទ្រដល់គោលដៅអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចបាននូវគោលនយោបាយជាអាទិភាពនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ព្រមទាំងផែនការរបស់ក្រសួង ស្ថាប័ន ដែលមានចែងនៅក្នុងផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣

(២) ពិនិត្យច្បាស់លាស់ការវិភាជតាមវិស័យអាទិភាពដែលមានចែងនៅក្នុងផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣

(៣) ពិនិត្យលទ្ធផលនៃកិច្ចពិភាក្សារវាងមន្ត្រីរបស់ក្រសួង ស្ថាប័ននីមួយៗ និងនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការរៀបចំ*ផែនការយុទ្ធសាស្ត្រថវិការយៈពេលវែង*សម្រាប់ក្រសួង ស្ថាប័នរបស់ខ្លួន

(៤) ពិនិត្យច្បាស់លាស់ពីប្រភពធនធានជាសក្តានុពលក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

(៥) កំណត់*លំដាប់អាទិភាព* ចំពោះគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. នីមួយៗ ដែលក្រសួង ស្ថាប័នបានផ្ញើមកក្រសួងផែនការ។ នាពេលសិក្ខាសាលាជាតិស្តីពីការផ្សព្វផ្សាយដំណើរការនៃការរៀបចំ*ក.វ.ស. ៣ឆ្នាំរំកិល២០១១-២០១៣* ក្រសួងផែនការបានបញ្ជាក់ច្បាស់ថា៖

- អាទិភាពគម្រោងមិនអាចមានលំដាប់ដូចគ្នានៅក្នុងក្រសួង ស្ថាប័នតែមួយ
- ចំពោះករណីគម្រោងអភិក្រមគ្រប់គ្រងទូទាំងវិស័យឬកម្មវិធីធំ ត្រូវផ្តល់ព័ត៌មានស្តីពីផ្នែកទាំងឡាយនៃគម្រោងដែលអាចទទួលបានហិរញ្ញប្បទានជាគម្រោង ព្រមទាំងគម្រោងតាមផ្នែកផ្សេងៗទៀតដែលត្រូវការនូវការកំណត់លំដាប់អាទិភាពដោយផ្អែកលើរយៈពេលនៃការអនុវត្តសកម្មភាពអភិក្រមគ្រប់គ្រងទូទាំងវិស័យឬសកម្មភាពដែលបានកំណត់របស់កម្មវិធីធំៗ
- ក្រសួងផែនការនឹងធ្វើការផ្តល់លេខគម្រោងដល់គ្រប់គម្រោង*ក.វ.ស. ៣ឆ្នាំរំកិល*ទាំងអស់ដែលថ្នាក់ដឹកនាំក្រសួង ស្ថាប័នបានកំណត់អាទិភាពនិងផ្ញើមកក្រសួងផែនការ។

១១- ក្រសួងផែនការធ្វើការវិភាជថវិកាសម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* ដោយមានមូលដ្ឋាននៃលក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖

- ការវិភាជសរុបសម្រាប់វិស័យដល់*គម្រោងកំពុងដំណើរការ*និង*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ត្រូវមានសង្គតិភាពជាមួយការវិភាជតាមវិស័យដែលមានចែងនៅក្នុង*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣*
- អាទិភាពនៃការវិភាជថវិកាដែលមានដល់បណ្តាគម្រោងកំពុងដំណើរការ ដើម្បីបន្តការអនុវត្តនិងបញ្ចប់ការអនុវត្ត
- ថវិកាដែលនៅសល់នឹងត្រូវធ្វើការវិភាជដល់គម្រោងសម្រាប់អនុវត្ត*ផ.យ.អ.ជ.* ដោយផ្អែកលើ៖
  - អាទិភាពនៃគម្រោងដែលកំណត់ដោយក្រសួង ស្ថាប័ន
  - គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ទាំងនោះសម្រាប់អនុវត្តយុទ្ធសាស្ត្រតាមវិស័យរបស់ក្រសួង ស្ថាប័ន ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងអាទិភាពដែលមានចែងនៅក្នុង*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣*
  - ព័ត៌មានដែលក្រសួង ស្ថាប័ន បានផ្ញើមកក្រសួងផែនការស្តីពីស្ថានភាពសក្តានុពលក្នុងការសន្យាផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្ត*ផ.យ.អ.ជ.*

- កិច្ចពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងកែសម្រួលឡើងវិញនូវការសន្យាផ្តល់ថវិកាពីកញ្ចប់ថវិកាជាតិ និងលទ្ធផលនៃកិច្ចពិភាក្សារវាងក្រសួង ស្ថាប័ន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការរៀបចំ*ផែនការយុទ្ធសាស្ត្រថវិកា*សម្រាប់ក្រសួង ស្ថាប័ននីមួយៗ

១២- ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃ*ក.វ.ស. ៣ឆ្នាំរំកិល* ក្រសួងផែនការបានរៀបចំកែសម្រួលឡើងវិញនូវប្រព័ន្ធទិន្នន័យរបស់*ក.វ.ស. ៣ឆ្នាំរំកិល* និងបញ្ជីសំណួរ រួចផ្ញើទៅក្រសួង ស្ថាប័នទាំងអស់សម្រាប់ឲ្យមន្ត្រីរបស់ក្រសួង ស្ថាប័នទាំងនោះបំពេញតាមប្រព័ន្ធកុំព្យូទ័រ និងផ្ញើត្រឡប់មកក្រសួងផែនការវិញ។

១៣- នៅក្នុង*ក.វ.ស. ៣ឆ្នាំរំកិល* ឆ្នាំមុនៗ (មុន*ក.វ.ស. ៣ឆ្នាំរំកិល២០១១-២០១៣*) ក្រសួងផែនការបានរៀបចំរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង *ក.វ.ស. ៣ឆ្នាំរំកិល* នៅឆ្នាំមុន។ ប៉ុន្តែបច្ចុប្បន្ននេះ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានរៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយ ដែលរួមមានការវិភាគលើការបន្ស៊ីធនធានដែលបានផ្តល់ជាមួយនឹងការវិភាជតាមវិស័យមានចែងនៅក្នុង*ផ.យ.អ.ជ.*។ ដូច្នេះ *ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* ក៏បន្តមិនដាក់បញ្ចូលនូវរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង*ក.វ.ស. ៣ឆ្នាំរំកិល* នៅឆ្នាំមុនទៀតដែរ។

១៤- បន្ទាប់ពីសេចក្តីផ្តើមនៃ*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦*នឹងមានបង្ហាញពីព័ត៌មានស្តីពីទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤-២០១៦ ក្នុងជំពូកទី២។ ជំពូកទី៣ បង្ហាញពីព័ត៌មានស្តីពី*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* និងជំពូកទី៤ បង្ហាញពីសេចក្តីសន្និដ្ឋាន។

# ជំពូកទី២
# ទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤-២០១៦

## ក. ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប២០១៤-២០១៦

១៥- នេះជាឆ្នាំទី៦នៃវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកដែលចាប់ផ្តើមក្នុងឆ្នាំ២០០៧ នៅក្នុងប្រទេសអភិវឌ្ឍជាច្រើន បានជះឥទ្ធិពលនិងប៉ះពាល់ដល់វិស័យសំខាន់ៗមួយចំនួននៃសេដ្ឋកិច្ចរបស់កម្ពុជា ដែលធ្វើឲ្យកំណើនផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) បានធ្លាក់ចុះពី៦.៧ភាគរយក្នុងឆ្នាំ២០០៨មកនៅត្រឹមតែ០.១ភាគរយក្នុងឆ្នាំ២០០៩។ នៅក្នុងអំឡុងពេលវិបត្តិនេះ វិស័យកសិកម្មនិងសេវាកម្មនៅរក្សាកំណើនបានយ៉ាងល្អដែលបានជួយបំពេញនូវការធ្លាក់ចុះក្នុងវិស័យមួយចំនួនទៀត ជាពិសេសវិស័យឧស្សាហកម្ម និងវិស័យសេវាកម្មមានការកើនឡើងតិចតួចប្រមាណ២.៣ភាគរយ។ ដោយសាររាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយច្បាស់លាស់ បានធ្វើឲ្យកំណើនផ.ស.ស.កើនឡើងខ្ពស់វិញ គឺ៦ភាគរយនៅឆ្នាំ២០១០ ៧.១ភាគរយក្នុងឆ្នាំ២០១១ និងកើនដល់៧.៣ភាគរយ ក្នុងឆ្នាំ២០១២។ ជាក់ស្តែងកំណើនផ.ស.ស. បានមកពីការរួមចំណែកធំរបស់វិស័យកសិកម្ម ដូច្នេះ តាមការប៉ាន់ស្មានកំណើនផ.ស.ស. នឹងស្ថិតក្នុងរង្វង់៧ភាគរយនៅក្នុងឆ្នាំ២០១២ និងពីរឆ្នាំក្រោយទៀត។ ការព្យាករពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ សម្រាប់ឆ្នាំ២០១៣-២០១៦ មានបង្ហាញក្នុងតារាងទី១។

១៦- នាបណ្តាឆ្នាំ២០០៩ ២០១០ និងឆ្នាំ២០១១ គឺរាជរដ្ឋាភិបាលបានប្រើប្រាស់គោលនយោបាយរូបិយវត្ថុងាយស្រួលដើម្បីជំរុញកំណើនតម្រូវការ ដូចជាការបង្កើតហេដ្ឋារចនាសម្ព័ន្ធនិងទំនុកចិត្តរបស់ប្រជាជន ជាពិសេសកម្លាំងពលកម្មក្នុងវិស័យវាយនភណ្ឌកាត់ដេរដែលកំពុងបាត់បង់ការងារ។ ក៏ប៉ុន្តែការគាំទ្ររបៀបនេះអាចជួយស្រោចស្រង់បានជាបណ្តោះអាសន្នប៉ុណ្ណោះ ឬអាចនិយាយបានថា សម្រាប់តែទំហំសេដ្ឋកិច្ចតូចៗដែលពឹងផ្អែកជាសំខាន់ ទៅលើទីផ្សារបរទេសសម្រាប់ផលិតផលរបស់ខ្លួន។ ទាំងអស់ដូចបានបង្ហាញខាងលើនេះ បញ្ជាក់ច្បាស់ថា បរិមាណផលិតផលដែលមានចំនួនកំណត់សម្រាប់ផ្គត់ផ្គង់នឹងបន្តក្នុងរយៈពេលខ្លីនិងមធ្យម ដែលជាឧបសគ្គរាំងដល់ការកាន់កាប់សេដ្ឋកិច្ច។ ដើម្បីជម្នះបាននូវឧបសគ្គ រាជរដ្ឋាភិបាលកំពុងពង្រីកវិសាលភាពនិងពង្រឹងគុណភាពផលិតផលនិងសេវាកម្មរបស់ខ្លួនបន្ថែមទៀតសម្រាប់ពង្រីកនិងពង្រឹងសេដ្ឋកិច្ច។

### តារាងទី១-ការព្យាករពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច

| សូចនាករសេដ្ឋកិច្ច | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|
| *ផ.ស.ស.* (ថ្លៃបច្ចុប្បន្ន គិតជាពាន់លានរៀល) | ៦១,៥២៥ | ៦៨,៥១១ | ៧៥,៦៧០ | ៨៣,៣០៧ |
| *ផ.ស.ស.* (ថ្លៃបច្ចុប្បន្ន គិតជាលានដុល្លារអាមេរិក) | ១៥,១៩១ | ១៧,១២៨ | ១៨,៦៨៤ | ២០,៥៧០ |
| *ផ.ស.ស.* សម្រាប់ប្រជាជនម្នាក់ៗ (គិតជាដុល្លារអាមេរិក) | ១,០៣៦ | ១,១៥១ | ១,២៣៨ | ១,៣៤៥ |
| **អត្រាកំណើន *ផ.ស.ស. ពិត* (%)** | **៧.៦%** | **៧.០%** | **៧.០%** | **៧.០%** |
| | | | | |
| **អតិផរណា (ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ គិតជាភាគរយ)** | **៤.០%** | **៣.៥%** | **៣.៥%** | **៣.៥%** |
| | | | | |
| **ការវិនិយោគសរុប (% *ផ.ស.ស.*)** | **២៧.៣%** | **២៥.៤%** | **២៥.៥%** | **២៥.៧%** |
| ការវិនិយោគសាធារណៈ (% *ផ.ស.ស.*) | ៧.៧% | ៧.២% | ៧.២% | ៧.២% |
| ការវិនិយោគឯកជន (% *ផ.ស.ស.*) | ១៩.៥% | ១៨.២% | ១៨.៣% | ១៨.៥% |
| | | | | |
| **ចំណូលថវិកាសរុប (% *ផ.ស.ស.*)** | **១៤.៩%** | **១៥.៤%** | **១៥.៩%** | **១៦.៣%** |
| **ចំណាយថវិកាសរុប (% *ផ.ស.ស.*)** | **១៩.៩%** | **១៩.០%** | **១៩.៨%** | **១៩.៩%** |
| | | | | |

មានមូលដ្ឋានលើអត្រាប្តូរប្រាក់៤១០០រៀល = ១ដុល្លារអាមេរិក

*ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣*

***កំណត់សម្គាល់:*** *ការប្រើតួលេខក្នុងឯកសារនេះ ប្រើតាមប្រព័ន្ធអង់គ្លេស។*

១៧- រាជរដ្ឋាភិបាលកម្ពុជាមានផែនការច្បាស់លាស់សម្រាប់ការរៀបចំផ.យ.អ.ជ. ២០១៤-២០១៨ គឺវិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យផ្សេងៗទៀត និងបច្ចេកវិទ្យា នឹងត្រូវបានពង្រឹងនិងពង្រីកបន្ថែមដែលជាជំនួយដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដូចជា សហគ្រាសធុនតូចនិងមធ្យម (វិស័យអគ្គិសនីនិងវិស្វកម្ម) ឧស្សាហកម្មរ៉ែ និងកែច្នៃចំណីអាហារ។

## ខ- អត្រាកំណើនផ.ស.ស. ពិត(ថ្លៃថេរឆ្នាំ២០០០)ដោយសកម្មភាពសេដ្ឋកិច្ច

១៨- តាមរយៈបទពិសោធដែលទទួលបានពីការធ្លាក់ចុះនៃសេដ្ឋកិច្ចក្នុងឆ្នាំ២០០៩ និងកិច្ចខំឥតស្រាកស្រាន្តរបស់រាជរដ្ឋាភិបាល គឺយើងសម្រេចបានកំណើនពីវិស័យឧស្សាហកម្មកើនឡើងពីរខ្ទង់នៅឆ្នាំ២០១០ និងឆ្នាំ២០១១ និងវិស័យសំណង់ក៏មានកំណើនដូចឧស្សាហកម្មដែរ ដែលជាមូលដ្ឋានដែលជួយស្តារនូវកំណើនផ.ស.ស. ឡើងវិញនៅឆ្នាំ២០១០និងឆ្នាំ២០១១ បន្ទាប់ពីបាន

ធ្លាក់ចុះនៅឆ្នាំ២០០៩។ ការព្យាករពីអត្រាកំណើនផ.ស.ស. ដោយសកម្មភាពសេដ្ឋកិច្ច សម្រាប់ឆ្នាំ ២០១៣-២០១៦ មានបង្ហាញក្នុងតារាងទី២។

**តារាងទី២ អត្រាកំណើនផ.ស.ស. (ថ្លៃថេរឆ្នាំ២០០០) ដោយសកម្មភាពសេដ្ឋកិច្ច**

| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|
| **កសិកម្ម នេសាទ និងរុក្ខាប្រមាញ់** | **៤,២%** | **៤,២%** | **៤,០%** | **៤,០%** |
| ដំណាំ | ៤,១% | ៣,៨% | ៣,៥% | ៣,៤% |
| ការចិញ្ចឹមសត្វ | ១,៣% | ៦,០% | ៦,១% | ៦,៣% |
| ការនេសាទ | ៧,១% | ៤,៧% | ៤,៧% | ៤,៧% |
| រុក្ខាប្រមាញ់ | (១,៣%) | ១,៩% | ១,៩% | ១,៩% |
| **ឧស្សាហកម្ម** | **៩,៣%** | **៩,៩%** | **៩,១%** | **៨,៩%** |
| រ៉ែ | ២០,៣% | ២៣,៧% | ១៤,៥% | ១០,១% |
| កម្មន្តសាល | ៧,០% | ៨,៦% | ៨,៤% | ៨,៤% |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | ៦,៣% | ៦,៦% | ៦,៧% | ៦,៧% |
| វាយនភណ្ឌ សម្លៀកបំពាក់ | ៦,៥% | ៨,៨% | ៨,៧% | ៨,៦% |
| ឈើ ក្រដាស និងការបោះពុម្ព | ១១,៩% | ៩,៤% | ៨,៩% | ៨,៩% |
| ផលិតកម្មជ័រកៅស៊ូ | ១១,៧% | ៧,៨% | ៧,០% | ៧,០% |
| ផលិតកម្មផ្សេងៗទៀត | ១០,២% | ៩,១% | ៨,០% | ៨,៣% |
| អគ្គិសនី ឧស្ម័ន និងទឹក | ៨,៥% | ៧,៧% | ៧,០% | ៧,០% |
| សំណង់ | ១៧,២% | ១២,៨% | ១០,៩% | ១០,៨% |
| **សេវាកម្ម** | **៨,៨%** | **៦,៨%** | **៧,១%** | **៧,២%** |
| ពាណិជ្ជកម្ម | ៧,៧% | ៦,១% | ៦,៣% | ៦,៣% |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ១៣,៧% | ៩,៣% | ៩,៧% | ១០,០% |
| ការដឹកជញ្ជូននិងទូរគមនាគមន៍ | ៧,៨% | ៦,៦% | ៦,៧% | ៦,៧% |
| ហិរញ្ញវត្ថុ | ១២,៣% | ៩,៩% | ១០,១% | ១០,១% |
| រដ្ឋបាលសាធារណៈ | ៤,៥% | ៤,៣% | ៤,៥% | ៤,៨% |
| អចលនទ្រព្យនិងអាជីវកម្ម | ១០,៩% | ៩,៦% | ៩,២% | ៩,២% |
| សេវាកម្មផ្សេងៗទៀត | ៦,០% | ៣,៥% | ៤,៥% | ៤,៦% |
| | | | | |
| ពន្ធលើផលិតផល ដោយមិនគិតបញ្ចូលនូវការឧបត្ថម្ភធន | ៨,០% | ៦,៩% | ៨,២% | ៧,៧% |
| ការឧបត្ថម្ភធន | ៦,៣% | ៦,៨% | ៧,១% | ៦,៧% |
| ថ្លៃសេវាកម្មហិរញ្ញវត្ថុ | ១២,០% | ២១,៤% | ១០,១% | ១០,១% |
| **ផ.ស.ស. សរុប** | **៧,៦%** | **៧,០%** | **៧,០%** | **៧,០%** |

*ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

## គ- ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចបាននូវកំណើនផ.ស.ស.ដែលបានគ្រោងទុក

១៩- គំរូនៃសេដ្ឋកិច្ចវិទ្យាធ្លាប់ប្រើដើម្បីធ្វើការព្យាករពីសេដ្ឋកិច្ចសម្រាប់រយៈពេល៥ឆ្នាំ ពីឆ្នាំ ២០០៩ដល់២០១៣ ក៏អាចត្រូវបានប្រើប្រាស់ដើម្បីធ្វើការព្យាករពីការវិនិយោគសរុបដែលចាំបាច់ក្នុងការធ្វើឲ្យសម្រេចបាននូវ*កំណើនផ.ស.ស.* ដូចដែលបានគ្រោងទុក និងការបែងចែកនៃការវិនិយោគសរុបទៅតាមវិស័យសេដ្ឋកិច្ច។ ថ្វីបើភាពមានកម្រិតខ្លះពីគំរូនៃសេដ្ឋកិច្ចវិទ្យាក៏ដោយ ក៏លទ្ធផលនៃការវិភាគបង្ហាញថា ទឹកប្រាក់នៃការវិនិយោគសរុបចំនួន៥៩,០៤០.០ពាន់លានរៀល (១៤.៤ពាន់លានដុល្លារអាមេរិក) គឺជាតម្រូវការដើម្បីសម្រេចបាននូវកំណើន*ផ.ស.ស.* ដែលបានគ្រោងទុកសម្រាប់ដំណាក់កាលនៃ*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* និងដែលតម្រូវការសម្រាប់ឆ្នាំនីមួយៗប្រមាណ១៩,៦៨០.០ពាន់លានរៀល(៤.៨ពាន់លានដុល្លារអាមេរិក)។ ការព្យាករពីតម្រូវការសម្រាប់ការវិនិយោគសរុបនេះ មានការកើនឡើងប្រមាណ១១.៤ភាគរយ បើប្រៀបធៀបទៅនឹងការព្យាករពីដំបូងនៅក្នុងផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣។

២០- ប្រភពផ្តល់ហិរញ្ញប្បទានដល់វិនិយោគសរុបចំនួន៥៩,០៤០.០ពាន់លានរៀល ក្នុងអំឡុងពេល *ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* (មានបង្ហាញនៅក្នុងតារាងទី៣)៖

- វិនិយោគមូលធនរបស់វិស័យឯកជននឹងមានប្រមាណ៤២,២៣០.០ពាន់លានរៀល (១០.៣ពាន់លានដុល្លារអាមេរិក) សមមូលនឹង៧១.៥ភាគរយនៃវិនិយោគមូលធនសរុប
- វិនិយោគមូលធនវិស័យសាធារណៈនឹងមានប្រមាណ១៦,៨១០.០ពាន់លានរៀល (៤.១ពាន់លានដុល្លារអាមេរិក) សមមូលនឹង២៨.៥ភាគរយនៃវិនិយោគមូលធនសរុប។

២១- ប្រភពធនធានសម្រាប់តម្រូវការវិនិយោគពីក្នុងស្រុកនិងពីក្រៅប្រទេសសម្រាប់ផ្តល់ហិរញ្ញប្បទានដល់តម្រូវការវិនិយោគសរុប៥៩,០៤០.០ពាន់លានរៀល ក្នុងអំឡុងពេល*ក.វ.ស. ៣ឆ្នាំរំកិល ២០១៤-២០១៦*៖

- ២៩,៩៣០ពាន់លានរៀល(៧.៣ពាន់លានដុល្លារអាមេរិក) សមមូលនឹង៥០.៧ភាគរយនៃវិនិយោគមូលធនសរុបនឹងត្រូវបានទទួលពីប្រភពក្នុងស្រុក
- ២៩,១១០ពាន់លានរៀល(៧.១ពាន់លានដុល្លារអាមេរិក) សមមូលនឹង៤៩.៣ភាគរយនៃវិនិយោគមូលធនសរុបនឹងត្រូវបានទទួលពីប្រភពក្រៅប្រទេស។

**តារាងទី៣ ការវិនិយោគចាំបាច់ដើម្បីសម្រេចបានកំណើនផ.ស.ស. ដែលបានគ្រោងទុក និងធនធានដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់**

*(គិតជាលានដុល្លារអាមេរិក)*

| ប្រភពហិរញ្ញប្បទាន | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤ -២០១៦ |
|---|---|---|---|---|---|
| **វិនិយោគមូលធនសរុប** | **៤,១៤១.៥** | **៤,៣៤៥.៥** | **៤,៧៧២.៧** | **៥,២៩៣.៧** | **១៤,៤១១.៩** |
| • **វិនិយោគមូលធនវិស័យសាធារណៈ** | **១,១៧៥.០** | **១,២៣១.៦** | **១,៣៤៤.៤** | **១,៤៨៧.៩** | **៤,០៦៣.៩** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ២៨៩.៣ | ៣០៣.២ | ៣៣១.០ | ៣៦៦.៣ | ១,០០០.៥ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ៨៨៥.៨ | ៩២៨.៤ | ១,០១៣.៤ | ១,១២១.៦ | ៣,០៦៣.៤ |
| • **វិនិយោគមូលធនវិស័យឯកជន** | **២,៩៦៦.៥** | **៣,១១៣.៩** | **៣,៤២៨.៣** | **៣,៨០៥.៨** | **១០,៣៤៨.០** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ១,៧៥០.៨ | ១,៩០៤.៤ | ២,០៨១.២ | ២,២៩៧.៤ | ៦,២៨៣.០ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ១,២១៥.៧ | ១,២០៩.៥ | ១,៣៤៧.១ | ១,៥០៨.៥ | ៤,០៦៥.១ |
| **វិនិយោគមូលធនសរុប** | **៤,១៤១.៥** | **៤,៣៤៥.៥** | **៤,៧៧២.៧** | **៥,២៩៣.៧** | **១៤,៤១១.៩** |
| • វិនិយោគមូលធនរបស់វិស័យសាធារណៈ | **១,១៧៥.០** | **១,២៣១.៦** | **១,៣៤៤.៤** | **១,៤៨៧.៩** | **៤,០៦៣.៩** |
| • វិនិយោគមូលធនរបស់វិស័យឯកជន | **២,៩៦៦.៥** | **៣,១១៣.៩** | **៣,៤២៨.៣** | **៣,៨០៥.៨** | **១០,៣៤៨.០** |
| **វិនិយោគមូលធនសរុប** | **៤,១៤១.៥** | **៤,៣៤៥.៥** | **៤,៧៧២.៧** | **៥,២៩៣.៧** | **១៤,៤១១.៩** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ២,០៤០.១ | ២,២០៧.៦ | ២,៤១២.២ | ២,៦៦៣.៧ | ៧,២៨៣.៥ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ២,១០១.៥ | ២,១៣៧.៩ | ២, ៣៦០.៥ | ២,៦៣០.១ | ៧,១២៨.៥ |
| • **វិនិយោគមូលធនវិស័យសាធារណៈ** | **១,១៧៥.០** | **១,២៣១.៦** | **១,៣៤៤.៤** | **១,៤៨៧.៩** | **៤,០៦៣.៩** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ២៨៩.៣ | ៣០៣.២ | ៣៣១.០ | ៣៦៦.៣ | ១,០០០.៥ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស[១] | ៨៨៥.៨ | ៩២៨.៤ | ១,០១៣.៤ | ១,១២១.៦ | ៣,០៦៣.៤ |

[១] វិនិយោគជាទុន មិនរាប់បញ្ចូលបច្ចេកទេស

*ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

២២- ការបែងចែកលម្អិតនៃការវិនិយោគចាំបាច់ដើម្បីសម្រេចបានកំណើនផ.ស.ស. សរុប ដែលបានគ្រោងទុកតាមរយៈវិស័យសេដ្ឋកិច្ច ត្រូវបានបង្ហាញក្នុងតារាងទី៤។ ដើម្បីសម្រេចបានអត្រាកំណើនផ.ស.ស.សរុប ដែលបានគ្រោងទុកតាមវិស័យ ការវិនិយោគក្នុងក្រុមវិស័យសំខាន់ៗ រួមមានដូចខាងក្រោម៖

- វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវការទុនវិនិយោគចំនួន៨,៩៧៦.៥ពាន់លានរៀល(២,១៨៩.៤លានដុល្លារអាមេរិក) ដែលផ្តោតជាសំខាន់លើដំណាំស្រូវ ជាពិសេស ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់ការបង្កើនការនាំអង្ករទៅទីផ្សារអន្តរជាតិសម្រាប់រយៈពេលក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦

- វិស័យឧស្សាហកម្មទូទៅ រួមមានការរុករករ៉ែ កម្មន្តសាល អគ្គិសនី ឧស្ម័ន ទឹក និងសំណង់ នឹងត្រូវការទុនវិនិយោគចំនួន២៨,១៣៦.៧ពាន់លានរៀល(៦,៨៦២.៦លានដុល្លារអាមេរិក) សម្រាប់រយៈពេលក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦។ នៅក្នុងក្រុមនេះ អនុវិស័យកម្មន្តសាល (វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង) នឹងត្រូវការចំណែកធំជាងគេនៃការវិនិយោគ គឺមានចំនួនប្រមាណ១២,៩៨៧.៦ពាន់លានរៀល(៣,១៦៧.៧លានដុល្លារអាមេរិក) និងអនុវិស័យសំណង់ ត្រូវការចំណែកធំនៃការវិនិយោគ គឺមានចំនួន ៩,២២៤.៦ពាន់លានរៀល(២,២៤៩.៩លានដុល្លារអាមេរិក) ហើយអនុវិស័យអគ្គិសនី ឧស្ម័ននិងទឹក ត្រូវការទុនវិនិយោគចំនួនប្រមាណ៤,៤៤០.៣ពាន់លានរៀល(១,០៨៣លានដុល្លារអាមេរិក)
- វិស័យសេវាកម្មរួមមាន ពាណិជ្ជកម្ម សណ្ឋាគារ និងភោជនីយដ្ឋាន(ទេសចរណ៍) ដឹកជញ្ជូន និងទូរគមនាគមន៍ ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ និងអចលនទ្រព្យត្រូវការទុនវិនិយោគចំនួន២១,៩៧៥.៦ពាន់លានរៀល(៥,៣៥៩.៩លានដុល្លារអាមេរិក)។

**តារាងទី៤ វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗដើម្បីសម្រេចបានគោលដៅនៃកំណើនផ.ស.ស.**

*(គិតជាលានដុល្លារអាមេរិក)*

| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤ -២០១៦ |
|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **៦២៩.២** | **៦៨៥.៣** | **៧២៦.១** | **៧៧៨.០** | **២,១៨៩.៤** |
| ដំណាំ | ៥២៥.៥ | ៥៧២.៤ | ៦០៦.១ | ៦៤៨.៨ | ១,៨២៧.៣ |
| ចិញ្ចឹមសត្វ | ៣១.០ | ៣៤.៥ | ៣៧.៤ | ៤១.១ | ១១៣.០ |
| នេសាទ | ៤១.៣ | ៤៥.៣ | ៤៨.៤ | ៥២.៤ | ១៤៦.១ |
| ព្រៃឈើ | ៣១.៣ | ៣៣.២ | ៣៤.២ | ៣៥.៨ | ១០៣.២ |
| **ឧស្សាហកម្ម** | **២,០៩៧.៣** | **២,០៣៦.៦** | **២,២៧២.៥** | **២,៥៥៣.៥** | **៦,៨៦២.៦** |
| រ៉ែ | ១៤៦.៦ | ១០៣.៦ | ១២០.៩ | ១៣៧.៤ | ៣៦១.៩ |
| ផលិតកម្ម | ៩១៧.១ | ៩៤៧.៤ | ១,០៥០.១ | ១,១៧០.២ | ៣,១៦៧.៧ |
| -អាហារ ភេសជ្ជៈ និងថ្នាំជក់ | ៨៥.៨ | ៩៥.៧ | ១០៤.១ | ១១៤.៧ | ៣១៤.៥ |
| -វាយនភណ្ឌ | ៣៦១.៦ | ៣៦១.៩ | ៤០៦.៦ | ៤៥២.៩ | ១,២២១.៤ |
| -ឈើ ក្រដាស និងផ្នែកបោះពុម្ព | ២២.៣ | ២៥.៦ | ២៨.៤ | ៣១.៩ | ៨៥.៩ |
| -ផលិតកម្មជ័រកៅស៊ូ | ៣៣.៩ | ៣៨.៣ | ៤១.៨ | ៤៦.១ | ១២៦.២ |
| -ផលិតកម្មដទៃ | ៤១៣.៥ | ៤២៥.៩ | ៤៦៩.២ | ៥២៤.៦ | ១,៤១៩.៧ |
| អគ្គិសនី ឧស្ម័ន និងទឹកស្អាត | ២៩១.៤ | ៣២៨.៥ | ៣៥៨.៥ | ៣៩៦.០ | ១,០៨៣.០ |
| សំណង់ | ៧៤២.២ | ៦៥៧.១ | ៧៤៣.០ | ៨៤៩.៨ | ២,២៤៩.៩ |

| | | | | | |
|---|---|---|---|---|---|
| **សេវាកម្ម** | **១,៤១៥.០** | **១,៦២៣.៦** | **១,៧៧៤.១** | **១,៩៦២.២** | **៥,៣៥៩.៩** |
| ពាណិជ្ជកម្ម | ២៥១.៩ | ២៧៩.៩ | ៣០៣.៣ | ៣៣២.៨ | ៩១៦.០ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ២០១.៧ | ២៣១.៤ | ២៦៥.១ | ៣០៤.០ | ៨០០.៥ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ២៤៤.០ | ២៧២.៤ | ២៩៦.៤ | ៣២៦.៥ | ៨៩៥.៣ |
| ហិរញ្ញវត្ថុ | ៤៧.១ | ៥៤.១ | ៦០.៨ | ៦៩.១ | ១៨៤.០ |
| រដ្ឋបាលសាធារណៈ | ៣២៩.០ | ៣៩៨.១ | ៤២៤.២ | ៤៥៩.០ | ១,២៨១.៣ |
| អចលនទ្រព្យនិងធុរកិច្ច | ២០៤.៣ | ២៣៤.៤ | ២៦១.១ | ២៩៤.៤ | ៧៨៩.៩ |
| សេវាកម្មដទៃទៀត | ១៣៧.០ | ១៥៣.៣ | ១៦៣.៤ | ១៧៦.៤ | ៤៩៣.១ |
| **សរុប** | **៤,១៤១.៥** | **៤,៣៤៥.៥** | **៤,៧៧២.៧** | **៥,២៩៣.៧** | **១៤,៤១១.៩** |

*ប្រភពៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

## ឃ- ចំណូលនិងចំណាយថវិកា ២០១៤-២០១៦

២៣- ដោយសារវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកដែលបានកើតឡើងក្នុងប្រទេសអភិវឌ្ឍ បានជះឥទ្ធិពលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា ចំណូលថវិកាបានធ្លាក់ចុះពី១៣.៣ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០០៨ មក១១.៩ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០០៩។ ជាក់ស្តែង ចំណូលថវិកាត្រូវបានកើនឡើងវិញជាបន្តបន្ទាប់រហូតដល់១៣.២ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០១០ និងបន្តរក្សានៅកម្រិតដដែលនៅក្នុងឆ្នាំ២០១១ និងបានបន្តកើនដល់១៤.៥ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០១២ និង១៤.៩ភាគរយនៃផ.ស.ស.ក្នុងឆ្នាំ២០១៣។ ហើយត្រូវបានព្យាករថានឹងកើនដល់ជិត១៥.៤ភាគរយ នៅក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥។ ការព្យាករនេះមានកម្រិតប្រហាក់ប្រហែលទៅនឹងការរំពឹងទុក ដែលទាមទារនូវកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីសម្រេចបានកំណើនផ.ស.ស. ០.៥ភាគរយ ក្នុង១ឆ្នាំ សម្រាប់បំពេញតម្រូវការចំណាយចាំបាច់មួយចំនួន។

២៤- ការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាលដែលផ្តោតលើការការពារក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រពីផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោក ក៏ដូចជាការអនុវត្តវិធានការសម្រាប់ជំរុញតម្រូវការ តាមរយៈកញ្ចប់គោលនយោបាយសម្រាប់ជំរុញកំណើន ជាពិសេសការផ្តល់ការឧបត្ថម្ភដល់កម្មករកាត់ដេរដែលបាត់បង់ការងារ កម្មករដែលបាត់បង់ការងារ និងការចំណាយច្រើនសម្រាប់កម្មវិធីកាត់បន្ថយភាពក្រីក្របានធ្វើឲ្យចំណាយថវិកាជាសមាមាត្រនៃផ.ស.ស.សរុប បានកើនឡើងពី១៥.៩ភាគរយក្នុងឆ្នាំ២០០៨ ដល់២០.៥ភាគរយក្នុងឆ្នាំ២០០៩ និងដល់២១.៣ភាគរយក្នុងឆ្នាំ២០១០ និងបានធ្លាក់ចុះបន្តិចមក២០.៧ភាគរយក្នុងឆ្នាំ២០១១ និងបន្តធ្លាក់ចុះមកទាបជាង២០ភាគរយក្នុងឆ្នាំ២០១២និងឆ្នាំ២០១៣។ កម្រិតនៃការចំណាយនេះនឹងធ្លាក់ចុះមកនៅប្រមាណ១៨ភាគរយនៅក្នុងរយៈពេល

ពីរឆ្នាំក្រោយ តាមរយៈកិច្ចខិតខំប្រឹងប្រែងប្រមូលចំណូលបន្ថែមទៀត និងអាចរក្សាបាននូវឱនភាពថវិកាក្នុងកម្រិត២ទៅ៣ភាគរយ។

២៥- ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងអនុវត្តដំណើរការចំនួនពីរ ដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ។ ទីមួយគឺ*ក្របខ័ណ្ឌចំណាយសម្រាប់រយៈមធ្យម* ដែលព្យាករពីតួលេខចំណាយចរន្តសម្រាប់រយៈពេល៣ឆ្នាំខាងមុខ។ ការព្យាករនេះនឹងត្រូវធ្វើបច្ចុប្បន្នកម្មរៀងរាល់ឆ្នាំ។ ការព្យាករផ្អែកលើការវិភាគម៉ាក្រូសេដ្ឋកិច្ចពីលើចុះក្រោម ដោយមើលលើការអនុវត្តនៃសេដ្ឋកិច្ចគោលនយោបាយអាទិភាព ក៏ដូចជាព័ត៌មានបានពីស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ ទីពីរគឺ*ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកាសម្រាប់រយៈពេល៣ឆ្នាំ* ដែលអនុវត្តតាមអភិក្រមពីក្រោមទៅលើ។ ធាតុចូលដែលសម្រាប់យកមកប្រើប្រាស់ក្នុងការវិភាគនេះ ផ្អែកលើព័ត៌មានដែលប្រមូលបានពីការផ្លាស់ប្តូរយោបល់រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងព័ត៌មាន ស្តីពីចំណាយនិងតម្រូវការរយៈពេលពីរឆ្នាំទៅមុខនៃស្ថាប័នទាំងនោះ។ ក្នុងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពង្រឹងភាពផ្សារភ្ជាប់គ្នានៃដំណើរការទាំងពីរ ដើម្បីកែលម្អការរៀបចំថវិកាប្រចាំឆ្នាំ។

## ខ- ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១៤-២០១៦

២៦- រាជរដ្ឋាភិបាលបានកំណត់ចំណុចដៅនៃតម្រូវការវិនិយោគរបស់វិស័យសាធារណៈដែលអាចមានតម្លៃប្រមាណ២៥,៧៤០.៦ពាន់លានរៀល(៦.៣ពាន់លានដុល្លារអាមេរិក) ដើម្បីអនុវត្ត គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នៃរដ្ឋសភា។ តម្លៃប៉ាន់ស្មាន នេះ រួមបញ្ចូលនូវៈ *(១)* តម្រូវការវិនិយោគមូលធនសម្រាប់វិស័យសាធារណៈដែលអាចមាន ប្រមាណ ១៧,៥៤០.៦ពាន់លានរៀល(៤,២៧៨ពាន់លានដុល្លារអាមេរិក) *(២)* ធនធានដែល ត្រូវការជាចាំបាច់ដើម្បីផ្តល់ការគាំទ្រដែលមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍ ការធ្វើពិពិធ-កម្មសេដ្ឋកិច្ចជនបទសំដៅកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល និងការផ្តល់ការគាំទ្របន្ទាន់ដល់ការសម្រាលផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោក និងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកទៅលើប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះ ដែលអាចមានប្រមាណ៤,១០០ពាន់លានរៀល(១ពាន់លានដុល្លារអាមេរិក) *(៣)* ធនធានដែលត្រូវការជាចាំបាច់ ដើម្បីពង្រីកសេវាសង្គមកិច្ចសំដៅឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃ*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា* ដែលអាចមានប្រមាណ២,០៥០ពាន់លានរៀល(០.៥ពាន់លានដុល្លារអាមេរិក) និង*(៤)* ធនធានដែលត្រូវការជាចាំបាច់ ដើម្បីពង្រឹងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតកម្មវិធីនិងការផ្តល់នូវសេវាកម្មប្រកបដោយប្រសិទ្ធភាព ដែលអាចមានប្រមាណ២,០៥០ពាន់លានរៀល(០.៥ពាន់លានដុល្លារអាមេរិក)។

**តារាងទី៥-ចំណុចដៅនៃការកៀរគរធនធានសម្រាប់វិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០១៤-២០១៦**

| តម្រូវការវិនិយោគវិស័យសាធារណៈ | ២០១៤-២០១៦ | |
|---|---|---|
| | ពាន់លានរៀល | លានដុល្លារអាមេរិក |
| ១. វិនិយោគមូលធនរបស់វិស័យសាធារណៈ (ការព្យាករម៉ាក្រូសេដ្ឋកិច្ច) | ១៦,៦៦២.០ | ៤,០៦៣.៩ |
| ២. ការគាំទ្រដែលមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍនិងពិពិធកម្មសេដ្ឋកិច្ចជនបទដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាលនិងដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកដែលមានផលប៉ះពាល់ទៅលើក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រ | ២,៥៤៥.៣ | ៦២០.៨ |
| ៣. ការពង្រីកសេវាសង្គមកិច្ចដើម្បីឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃ*គ.អ.ស.ក.* | ១,២៧៣.១ | ៣១០.៥ |
| ៤. ការគាំទ្រដល់ការពង្រឹងសមត្ថភាពនៃស្ថាប័នរបស់*រាជរដ្ឋាភិបាលកម្ពុជា* ក្នុងការបង្កើតកម្មវិធីនិងការផ្តល់នូវសេវាកម្ម ប្រកបដោយប្រសិទ្ធភាព | ១,២៥២.៦ | ៣០៥.៥ |
| ***សរុប*** | ***២១,៧៣៣.៤*** | ***៥,៣០០.៧*** |

*ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងផែនការ*

២៧- សម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* គឺត្រូវការថវិកាសរុបប្រមាណ១៦,៦៦២ពាន់លានរៀល(៤,០៦៣.៩លានដុល្លារអាមេរិក) ឬប្រមាណ៥,២៤៣ពាន់លានរៀល(១,២៧៨លានដុល្លារអាមេរិក) ក្នុងមួយឆ្នាំដូចមានបង្ហាញនៅតារាងទី៣។ បរិមាណតម្រូវការថវិកាសរុបសម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* នេះ គឺមានការកើនឡើងខ្ពស់ជាងការវិភាជនៅក្នុង*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣*។ បរិមាណថវិកាសរុបសម្រាប់អនុវត្ត*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* ប្រមាណ១៦,៦៦២ពាន់លានរៀល(៤,០៦៣.៩លានដុល្លារអាមេរិក) ដែលក្នុងនោះហិរញ្ញប្បទានក្នុងស្រុកដោយរាជរដ្ឋាភិបាលមាន៤,១០២.១ពាន់លានរៀល(១,០០០.៥លានដុល្លារអាមេរិក) និងចំណែកដែលនៅសល់១២,៥៥៩.៩ពាន់លានរៀល(៣,០៦៣.៤លានដុល្លារអាមេរិក)ឬប្រមាណ៤,១៨៦.៥ពាន់លានរៀល(១,០២១.១លានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ អាចត្រូវបានធ្វើហិរញ្ញប្បទានពីប្រភពដូចខាងក្រោម៖

- ហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍក្រៅប្រទេសជាប្រពៃណី(ភាគច្រើនពីដៃគូអភិវឌ្ឍទ្វេភាគី ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល)
- កម្ចីសម្បទានពីដៃគូអភិវឌ្ឍក្រៅប្រទេស(ភាគច្រើនពីស្ថាប័នហិរញ្ញវត្ថុពហុភាគីនិងទ្វេភាគីសំខាន់ៗ)
- ធនធានពីប្រភពដៃគូអភិវឌ្ឍមិនមែនប្រពៃណី(ហិរញ្ញប្បទានឥតសំណងនិងកម្ចីពាក់កណ្តាលសម្បទាន)
- ចំណូលថ្មីៗដែលអាចបានមកពីការអភិវឌ្ឍឧស្សាហកម្មអាជីវកម្មរ៉ែ។

២៨- រាជរដ្ឋាភិបាលកម្ពុជាមានជំនឿជឿជាក់ថា តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈដែលមានប្រមាណ១២,៥៥៩.៩ពាន់លានរៀល(៣,០៦៣.៤ លានដុល្លារអាមេរិក) ឬប្រមាណ

៤,១៨៦.៥ពាន់លានរៀល(១,០២១.១លានដុល្លារអាមេរិក)ក្នុងមួយឆ្នាំ អាចនឹងទទួលបានពីការបន្តគាំទ្រពីដៃគូអភិវឌ្ឍជាប្រពៃណីនិងមិនមែនជាប្រពៃណី និងពីចំណូលបន្ថែមថ្មីពីប្រេងឧស្ម័ន និងធនធានរ៉ែ នៅពេលដែលអាជីវកម្មនេះត្រូវបានដំណើរការជាលក្ខណៈពាណិជ្ជកម្ម។ ក៏ប៉ុន្តែការកៀរគរហិរញ្ញប្បទានបន្ថែមពីដៃគូ ដូចជាមិនបានបង្ហាញពីភាពងាយស្រួលនោះឡើយ ដោយសារដៃគូភាគច្រើនបានសន្យាផ្តល់រួចមកហើយ និងដើម្បីសម្រេចបានហិរញ្ញប្បទានគ្រប់ចំនួន គឺត្រូវខិតខំស្វែងរកបន្ថែមទៀតនូវដៃគូថ្មីផ្សេងៗទៀត។ សម្រាប់រាជរដ្ឋាភិបាល គឺត្រូវពិនិត្យឲ្យច្បាស់លាស់នូវកំណែទម្រង់សេដ្ឋកិច្ច ដូចជាការបង្កើនទិន្នផលស្រូវនិងការនាំចេញ និងការធ្វើពិពិធកម្មដំណាំផ្សេងៗក្រៅពីដំណាំស្រូវ ជាពិសេសសម្រាប់អនាគត ត្រូវគ្រប់គ្រងចំណូលទទួលបានពីអាជីវកម្មរ៉ែ ដីសម្បទាន និងចំណូលពន្ធ។

២៩- វិភាជន៍តាមវិស័យនិងអនុវិស័យនៃតម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ សម្រាប់ឆ្នាំ ២០១៤-២០១៦ នៅក្នុងតារាងទី៦ខាងក្រោម គឺមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យចែងនៅក្នុងតារាងទី២៦ នៃ*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣*។

**តារាងទី៦ វិភាជន៍តាមវិស័យនិងអនុវិស័យសម្រាប់តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដោយមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យចែងនៅក្នុងផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣**

| វិស័យ | បរិមាណវិភាជន៍ ២០១៤-២០១៦ | | ភាគរយ | ជនបទ | ភាគរយ | ទីប្រជុំជន | ភាគរយ |
|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | លានដុល្លារអាមេរិក | | | | | |
| **វិស័យសង្គមកិច្ច** | | | | | | | |
| អប់រំ : ក្នុងនោះ ការអប់រំមូលដ្ឋាន៦០% | ១,៨៨៧.០ | ៤៦០.៤ | ១២.០ | ១,១៣២.៥ | ៦០.០ | ៧៥៥.០ | ៤០.០ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៦២៩.០ | ១៥៣.៥ | ៤.០ | ៣១៤.៦ | ៥០.០ | ៣១៤.៦ | ៥០.០ |
| សុខាភិបាល៤០% | ១,៨៨៧.០ | ៤៦០.៤ | ១២.០ | ១,៣២១.២ | ៧០.០ | ៥៦៦.២ | ៣០.០ |
| កម្មវិធីដើម្បីជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុពិភពលោកលើជនងាយរងគ្រោះនិងអ្នកក្រ | ៦២៩.០ | ១៥៣.៥ | ៤.០ | ៥០៣.៣ | ៨០.០ | ១២៥.៨ | ២០.០ |
| **សរុប** | **៥,០៣៣.០** | **១,២២៧.៦** | **៣២.០** | **៣,២៧១.៦** | **៦៥.០** | **១,៧៦១.៦** | **៣៥.០** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី : ក្រៅពីដំណាំ | ៦២៩.០ | ១៥៣.៥ | ៤.០ | ៥៩៧.៧ | ៩៥.០ | ៣១.៥ | ៥.០ |
| ដំណាំតាមរដូវ : ស្រូវនិងផ្សេងៗ | ៦២៩.០ | ១៥៣.៥ | ៤.០ | ៦២៩.២ | ១០០ | ០.០ | ០.០ |
| អភិវឌ្ឍន៍ជនបទ | ១,៨៨៧.០ | ៤៦០.៤ | ១២.០ | ១,៨៨៧.៥ | ១០០ | ០.០ | ០.០ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៦២៩.០ | ១៥៣.៥ | ៤.០ | ២៥១.៧ | ៤០.០ | ៣៧៧.៥ | ៦០.០ |
| **សរុប** | **៣,៧៧៥.០** | **៩២០.៧** | **២៤.០** | **៣,៣៦៧.៣** | **៨៩.០** | **៤០៧.៧** | **១១.០** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | |
| ដឹកជញ្ជូន ( ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១,៨៨៧.0 | ៤៦0.៤ | ១២.0 | ៩៤៣.៧ | ៥0.0 | ៩៤៣.៧ | ៥0.0 |
| ទឹកនិងអនាម័យ( មិនគិតនៅជនបទ) | ៦២៩.0 | ១៥៣.៥ | ៤.0 | ១៥៧.៣ | ២៥.0 | ៤៧១.៩ | ៧៥.0 |
| ថាមពលនិងអគ្គិសនី | ៦២៩.0 | ១៥៣.៥ | ៤.0 | ៣១៤.៦ | ៥0.0 | ៣១៤.៦ | ៥0.0 |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១៥៧.0 | ៣៨.៤ | ១.0 | ៧៨.៦ | ៥0.0 | ៧៨.៦ | ៥0.0 |
| **សរុប** | **៣,៣0៣.0** | **៨0៥.៦** | **២១.0** | **១,៤៩៣.0** | **៤៥.0** | **១,៨១0.១** | **៥៥.0** |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | | | | | |
| ការបញ្ជ្រាបយេនឌ័រ | ២៣៦.0 | ៥៧.៥ | ១.៥ | ៧0.៨ | ៣0.0 | ១៦៦.២ | ៧0.0 |
| ទេសចរណ៍ | ៣១៥.0 | ៧៦.៧ | ២.0 | ៧៨.៦ | ២៥.0 | ២៣៥.៩ | ៧៥.0 |
| បរិស្ថាននិងការអភិរក្ស | ៦២៩.0 | ១៥៣.៥ | ៤.0 | ៥៦៦.២ | ៩0.0 | ៦២.៩ | ១0.0 |
| សហគមន៍និងសេវាកម្មសង្គម | ៦២៩.0 | ១៥៣.៥ | ៤.0 | ៤៧១.៩ | ៧៥.0 | ១៥៧.៣ | ២៥.0 |
| វប្បធម៌និងសិល្បៈ | ២៣៦.0 | ៥៧.៥ | ១.៥ | ១១៨.0 | ៥0.0 | ១១៨.0 | ៥0.0 |
| អភិបាលកិច្ចនិងរដ្ឋបាល | ១,២៥៨.0 | ៣0៦.៩ | ៨.0 | ៥0៣.៣ | ៤0.0 | ៧៥៥.0 | ៦0.0 |
| **សរុប** | **៣,៣0៣.0** | **៨0៥.៦** | **២១.0** | **១,៨១0.១** | **៥៥.0** | **១,៤៨៦.៤** | **៤៥.0** |
| មិនទាន់បែងចែក | ៣១៥.0 | ៧៦.៧ | ២.0 | ១៥៧.៣ | ៥0.0 | ១៥៧.៣ | ៥0.0 |
| **សរុបរួម** | **១៥,៧២៩.0** | **៣,៨៣៦.៤** | **១00.0** | **១0,0៩៨.0** | **៦៤.0** | **៥,៦៣១.0** | **៣៦.0** |

*ប្រភព៖ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២00៩-២០១៣*

# ជំពូកទី៣

## កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៤-២០១៦

៣០- ដូចបានបង្ហាញក្នុងជំពូកមុនដែរ សម្រាប់ការអនុវត្ត*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣* (រយៈពេលប្រាំឆ្នាំ) រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប៉ាន់ស្មានតម្លៃសរុបចំនួន២៥,៧៤០.៦ពាន់លានរៀល(៦,២៧៨.១លានដុល្លារអាមេរិក) សម្រាប់បំពេញតម្រូវការវិនិយោគវិស័យសាធារណៈ ដើម្បីឈានទៅសម្រេចបានការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី៤។ ការវិភាជសម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* មានចំនួន១៥,៧២៩ពាន់លានរៀល(៣,៨៣៦.៤លានដុល្លារអាមេរិក) (តារាងទី៧) និងដូចមានចែងនៅក្នុងក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម គឺរាជរដ្ឋាភិបាលកម្ពុជាបានវិភាជថវិកាជាតិ ចំនួន៤,២១៧.៦ពាន់លានរៀល (១,០២៨.៧លានដុល្លារអាមេរិក) សម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦*។

**តារាងទី៧-ការវិភាជតាមវិស័យនិងអនុវិស័យ សម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុង ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ និងក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦**

| វិស័យនិងអនុវិស័យ | គោលដៅវិនិយោគសាធារណៈក្នុងផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ | | | | | |
|---|---|---|---|---|---|---|
| | ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ | | | ក.វ.ស. ២០១៤-២០១៦ | | |
| | ពាន់លានរៀល | លានដុល្លារអាមេរិក | ភាគរយ | ពាន់លានរៀល | លានដុល្លារអាមេរិក | ភាគរយ |
| **វិស័យសង្គមកិច្ច** | | | | | | |
| អប់រំ : (ក្នុងនោះ ការអប់រំមូលដ្ឋាន៦០%) | ៣,០៨៨.៩ | ៧៥៣.៤ | ១២.០ | ១,៨៨៧.០ | ៤៦០.៤ | ១២.០ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១,០២៩.៦ | ២៥១.១ | ៤.០ | ៦២៩.០ | ១៥៣.៥ | ៤.០ |
| សុខាភិបាល | ៣,០៨៨.៩ | ៧៥៣.៤ | ១២.០ | ១,៨៨៧.០ | ៤៦០.៤ | ១២.០ |
| កម្មវិធីដើម្បីជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុពិភពលោកលើជនងាយរងគ្រោះនិងអ្នកក្រ | ១,០២៩.៦ | ២៥១.១ | ៤.០ | ៦២៩.០ | ១៥៣.៥ | ៤.០ |
| **សរុប** | **៨,២៣៧.០** | **២,០០៩.០** | **៣២.០** | **៥,០៣៣.០** | **១,២២៧.៦** | **៣២.០** |
| **វិស័យសេដ្ឋកិច្ច** | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី : ក្រៅពីដំណាំ | ១,០២៩.៦ | ២៥១.១ | ៤.០ | ៦២៩.០ | ១៥៣.៥ | ៤.០ |
| ដំណាំតាមរដូវ : ស្រូវនិងផ្សេងៗ | ១,០២៩.៦ | ២៥១.១ | ៤.០ | ៦២៩.០ | ១៥៣.៥ | ៤.០ |
| អភិវឌ្ឍន៍ជនបទ | ៣,០៨៨.៩ | ៧៥៣.៤ | ១២.០ | ១,៨៨៧.០ | ៤៦០.៤ | ១២.០ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ១,០២៩.៦ | ២៥១.១ | ៤.០ | ៦២៩.០ | ១៥៣.៥ | ៤.០ |
| **សរុប** | **៦,១៧៧.៧** | **១,៥០៦.៨** | **២៤.០** | **៣,៧៧៥.០** | **៩២០.៧** | **២៤.០** |

| | | | | | | |
|---|---|---|---|---|---|---|
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | |
| ដឹកជញ្ជូន( ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍ ) | ៣,០៨៨.៩ | ៧៥៣.៤ | ១២.០ | ១,៨៨៧.០ | ៤៦០.៤ | ១២.០ |
| ទឹកនិងអនាម័យ ( មិនគិតនៅជនបទ) | ១,០២៩.៦ | ២៥១.១ | ៤.០ | ៦២៩.០ | ១៥៣.៥ | ៤.០ |
| ថាមពលនិងអគ្គិសនី | ១,០២៩.៦ | ២៥១.១ | ៤.០ | ៦២៩.០ | ១៥៣.៥ | ៤.០ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ២៥៧.៤ | ៦២.៨ | ១.០ | ១៥៧.០ | ៣៨.៤ | ១.០ |
| **សរុប** | **៥,៤០៥.៥** | **១,៣១៨.៤** | **២១.០** | **៣,៣០៣.០** | **៨០៥.៦** | **២១.០** |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | | | | |
| ការបញ្ច្រាបយេនឌ័រ | ៣៨៦.១ | ៩៤.២ | ១.៥ | ២៣៦.០ | ៥៧.៥ | ១.៥ |
| ទេសចរណ៍ | ៥១៤.៨ | ១២៥.៦ | ២.០ | ៣១៥.០ | ៧៦.៧ | ២.០ |
| បរិស្ថាននិងការអភិរក្ស | ១,០២៩.៦ | ២៥១.១ | ៤.០ | ៦២៩.០ | ១៥៣.៥ | ៤.០ |
| សហគមន៍និងសេវាកម្មសង្គម | ១,០២៩.៦ | ២៥១.១ | ៤.០ | ៦២៩.០ | ១៥៣.៥ | ៤.០ |
| វប្បធម៌និងសិល្បៈ | ៣៨៦.២ | ៩៤.២ | ១.៥ | ២៣៦.០ | ៥៧.៥ | ១.៥ |
| អភិបាលកិច្ចនិងរដ្ឋបាល | ២,០៥៩.២ | ៥០២.២ | ៨.០ | ១,២៥៨.០ | ៣០៦.៩ | ៨.០ |
| **សរុប** | **៥,៤០៥.៥** | **១,៣១៨.៤** | **២១.០** | **៣,៣០៣.០** | **៨០៥.៦** | **២១.០** |
| មិនទាន់បែងចែក | ៥១៤.៨ | ១២៥.៦ | ២.០ | ៣១៥.០ | ៧៦.៧ | ២.០ |
| **សរុបរួម** | **២៥,៧៤០.៦** | **៦,២៧៨.២** | **១០០.០** | **១៥,៧២៩.០** | **៣,៨៣៦.៤** | **១០០.០** |

*ប្រភព: ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣*

## ក- សេចក្តីសង្ខេបនៃគម្រោងសម្រាប់ក.វ.ស.៣ឆ្នាំរំកិល២០១៤-២០១៦ ដែលបានទទួលពីក្រសួង ស្ថាប័ន

៣១- *ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* បានរៀបចំឡើងដោយមានមូលដ្ឋានលើធាតុចូលដែលបានទទួលពីគ្រប់ក្រសួង ស្ថាប័ន រួមមាន៖ *(១) គម្រោងកំពុងដំណើរការ* ជាគម្រោងដែលកំពុងអនុវត្តដោយមានឬពុំមានកិច្ចសហការប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និង*(២) គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(គម្រោងថ្មី)* ដែលក្រសួង ស្ថាប័ន មានគម្រោងអនុវត្តក្នុងអំឡុងពេលឆ្នាំ២០១៤-២០១៦។ *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣* បានចែងថា បរិមាណថវិកាចំនួន៦,២៧៨.១លានដុល្លារអាមេរិក នឹងត្រូវចំណាយសម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈសម្រាប់រយៈពេល៥ឆ្នាំ២០០៩-២០១៣ ចំណែកឯតម្រូវការវិនិយោគវិស័យសាធារណៈនៃ*ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦* មានចំនួន៣,៨៣៦.៤លានដុល្លារអាមេរិក។ ក៏ប៉ុន្តែក្រសួង ស្ថាប័ន ស្នើសុំសម្រាប់ដាក់បញ្ចូលទៅក្នុង*ក.វ.ស.៣ឆ្នាំរំកិល២០១៤-២០១៦* មានចំនួន៤,៧៣២លានដុល្លារអាមេរិក។ ព័ត៌មានសង្ខេបស្តីពីគម្រោង*ក.វ.ស.៣ឆ្នាំរំកិល២០១៤-២០១៦* ដែលបានស្នើឡើងដោយក្រសួង ស្ថាប័ន មានបង្ហាញនៅក្នុងតារាងទី៨៖

- តម្រូវការចំណាយប៉ាន់ស្មានសរុបសម្រាប់*ក.វ.ស.៣ឆ្នាំរំកិល២០១៤-២០១៦* តម្រូវការថវិកាសរុប៤,៧៣២.៤លានដុល្លារអាមេរិក
  - គម្រោងកំពុងដំណើរការ ២,៥៧៤.៥លានដុល្លារអាមេរិក
  - គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(ថ្មី) ២,១៥៧.៩លានដុល្លារអាមេរិក
- បរិមាណថវិកាដែលក្រសួង ស្ថាប័នបានរាយការណ៍ថា បានសន្យាផ្តល់២,៩៥២.១លានដុល្លារអាមេរិក
  - ថវិកាជាតិ ៦៧៣.៤លានដុល្លារអាមេរិក
  - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ២,២៧៨.៧លានដុល្លារអាមេរិក
  - សម្រាប់គម្រោងកំពុងដំណើរការ ២,១៩៦.៤លានដុល្លារអាមេរិក
    - ថវិកាជាតិ ២៦០.៩លានដុល្លារអាមេរិក
    - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ១,៩៣៥.៥លានដុល្លារអាមេរិក
  - សម្រាប់គម្រោងអនុវត្តផ.យ.អ.ជ.(ថ្មី) ៧៥៥.៧លានដុល្លារអាមេរិក
    - ថវិកាជាតិ ៤១២.៦លានដុល្លារអាមេរិក
    - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ៣៤៣.១លានដុល្លារអាមេរិក
- តម្រូវការថវិកាបំពេញបន្ថែម(បំពេញបន្ថែមបរិមាណហិរញ្ញប្បទានដែលបានសន្យា) ១,៧៨០.៣លានដុល្លារអាមេរិក
  - គម្រោងកំពុងដំណើរការ ៣៧៨.១លានដុល្លារអាមេរិក
  - គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ១,៤០២.២លានដុល្លារអាមេរិក

៣២- តារាងទី៩ នឹងធ្វើការបង្ហាញលម្អិតបន្ថែមនូវគម្រោងដែលក្រសួង ស្ថាប័នទាំងអស់ បានផ្ញើមកក្រសួងផែនការសម្រាប់ធ្វើការរៀបចំ*ក.វ.ស.៣ឆ្នាំរំកិល២០១៤-២០១៦* និងបានបែងចែកគម្រោងទាំងអស់នោះទៅតាមវិស័យអាទិភាពរបស់*ផ.យ.អ.ជ.បច្ចុប្បន្នកម្ម២០០៩-២០១៣*។ ព័ត៌មានគម្រោងទាំងនោះរួមមាន (១) តម្រូវការចំណាយប៉ាន់ស្មានសរុបទៅតាមឆ្នាំនីមួយៗពីឆ្នាំ ២០១៤-២០១៦ (២) បរិមាណហិរញ្ញប្បទានដែលក្រសួង ស្ថាប័នបានរាយការណ៍ថាបានសន្យាផ្តល់(ដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ) សម្រាប់គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. និង(៣) បរិមាណតម្រូវការហិរញ្ញប្បទានបំពេញបន្ថែមលើហិរញ្ញប្បទានដែលបានសន្យាផ្តល់រួចហើយក្នុងឆ្នាំនីមួយៗ។

## តារាងទី៨ សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ដែលក្រសួង ស្ថាប័នស្នើសុំសម្រាប់ក.វ.ស. ៣ឆ្នាំរំកិល២០១៤-២០១៦

*(គិតជា ពាន់ដុល្លារអាមេរិក)*

| | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៤ | ២០១៤ | ២០១៥ | សរុប ២០១៤-២០១៦ | ប្រភព ហិរញ្ញប្បទាន | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ |
| គម្រោងកំពុងដំណើរការ | | | | | រាជរដ្ឋាភិបាល | 135,892.3 | 72,896.0 | 52,100.0 | 260,888.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 933,385.0 | 629,666.3 | 372,279.6 | 1,935,510.9 | | | | |
| | 1,195,022.7 | 832,766.1 | 546,716.3 | 2,574,505.1 | សរុប | 1,069,277.3 | 702,562.3 | 424,379.6 | 2,196,399.2 | 125,745.4 | 130,203.8 | 122,336.6 | 378,105.9 |
| គម្រោងសម្រាប់អនុវត្ត ផយអជ | | | | | រាជរដ្ឋាភិបាល | 131,397.7 | 143,170.9 | 137,992.7 | 412,561.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 65,827.2 | 116,552.3 | 160,765.3 | 343,144.8 | | | | |
| | 458,511.1 | 687,421.4 | 1,011,952.4 | 2,157,884.9 | សរុប | 197,225.0 | 259,723.1 | 298,758.0 | 755,706.0 | 261,286.2 | 427,698.3 | 713,194.4 | 1,402,178.9 |
| សរុប | | | | | រាជរដ្ឋាភិបាល | 267,290.0 | 216,066.9 | 190,092.7 | 673,449.5 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 999,212.3 | 746,218.5 | 533,044.9 | 2,278,655.7 | | | | |
| | 1,653,533.9 | 1,520,187.5 | 1,558,668.7 | 4,732,390.0 | សរុប | 1,266,502.2 | 962,285.4 | 723,137.6 | 2,952,105.2 | 387,031.6 | 557,902.1 | 835,531.1 | 1,780,284.8 |

# តារាងទី៩ គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. បែងចែកទៅតាមវិស័យអាទិភាពនៃ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ ដែលក្រសួងស្ថាប័នស្នើសុំ

(ឯកតាគិតជាពាន់ដុល្លារអាមេរិក)

| ក្រសួង ស្ថាប័ន | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ | ប្រភពហិរញ្ញប្បទាន | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ |
| **វិស័យសង្គមកិច្ច** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 230,013.4 | 227,301.0 | 182,152.1 | 639,466.5 | សរុប | 160,491.8 | 151,253.7 | 110,821.8 | 422,747.3 | 69,521.6 | 76,047.3 | 71,330.3 | 216,719.2 |
| | | | | | រាជរដ្ឋាភិបាល | 13,031.4 | 13,290.3 | 12,429.3 | 38,751.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 147,460.4 | 137,963.4 | 98,392.5 | 383,996.3 | | | | |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 25,710.5 | 37,650.5 | 36,673.4 | 100,034.4 | សរុប | 4,422.0 | 4,221.0 | 3,422.0 | 12,065.0 | 21,288.5 | 33,429.5 | 33,251.4 | 87,969.4 |
| | | | | | រាជរដ្ឋាភិបាល | 284.8 | 273.8 | 234.8 | 793.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 4,137.3 | 3,947.3 | 3,187.3 | 11,271.8 | | | | |
| សរុប | 255,724.0 | 264,951.5 | 218,825.5 | 739,500.9 | សរុប | 164,913.8 | 155,474.7 | 114,243.8 | 434,812.3 | 90,810.1 | 109,476.8 | 104,581.7 | 304,688.6 |
| | | | | | រាជរដ្ឋាភិបាល | 13,316.2 | 13,564.0 | 12,664.0 | 39,544.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 151,597.6 | 141,910.7 | 101,579.8 | 395,268.1 | | | | |
| **1. ក្រសួងសុខាភិបាល** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 86,077.2 | 84,333.3 | 64,367.1 | 234,777.6 | សរុប | 61,271.0 | 55,114.7 | 39,634.4 | 156,200.2 | 24,806.2 | 29,218.6 | 24,732.7 | 78,577.5 |
| | | | | | រាជរដ្ឋាភិបាល | 7,304.9 | 7,452.4 | 6,539.5 | 21,296.9 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 53,966.1 | 47,662.3 | 33,094.9 | 134,903.3 | | | | |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 880.0 | 880.0 | 880.0 | 2,640.0 | សរុប | | | | | 880.0 | 880.0 | 880.0 | 2,640.0 |
| | | | | | រាជរដ្ឋាភិបាល | | | | | | | | |
| | | | | | ដៃគូអភិវឌ្ឍ | | | | | | | | |
| សរុប | 86,957.2 | 85,213.3 | 65,247.1 | 237,417.6 | សរុប | 61,271.0 | 55,114.7 | 39,634.4 | 156,200.2 | 25,686.2 | 30,098.6 | 25,612.7 | 81,217.5 |
| | | | | | រាជរដ្ឋាភិបាល | 7,304.9 | 7,452.4 | 6,539.5 | 21,296.9 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 53,966.1 | 47,662.3 | 33,094.9 | 134,903.3 | | | | |
| **2. ក្រសួងអប់រំ យុវជន និងកីឡា** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 50,425.7 | 50,017.2 | 23,849.8 | 124,292.7 | សរុប | 47,975.7 | 47,567.2 | 23,849.8 | 119,392.7 | 2,450.0 | 2,450.0 | | 4,900.0 |
| | | | | | រាជរដ្ឋាភិបាល | 1,200.0 | 1,200.0 | 1,200.0 | 3,600.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 46,775.7 | 46,367.2 | 22,649.8 | 115,792.7 | | | | |

| ក្រសួង ស្ថាប័ន | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ | ប្រភពហិរញ្ញប្បទាន | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 13,847.9 | 26,926.0 | 26,105.5 | 66,879.4 | សរុប | | | | | 13,847.9 | 26,926.0 | 26,105.5 | 66,879.4 |
| | | | | | រាជរដ្ឋាភិបាល | | | | | | | | |
| | | | | | ដៃគូអភិវឌ្ឍ | | | | | | | | |
| សរុប | 64,273.6 | 76,943.2 | 49,955.3 | 191,172.1 | សរុប | 47,975.7 | 47,567.2 | 23,849.8 | 119,392.7 | 16,297.9 | 29,376.0 | 26,105.5 | 71,779.4 |
| | | | | | រាជរដ្ឋាភិបាល | 1,200.0 | 1,200.0 | 1,200.0 | 3,600.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 46,775.7 | 46,367.2 | 22,649.8 | 115,792.7 | | | | |
| **3. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 8,979.7 | 4,193.1 | 740.0 | 13,912.8 | សរុប | 8,979.7 | 4,193.1 | 740.0 | 13,912.8 | | | | |
| | | | | | រាជរដ្ឋាភិបាល | 300.0 | 200.0 | 30.0 | 530.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 8,679.7 | 3,993.1 | 710.0 | 13,382.8 | | | | |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 10,982.6 | 9,844.5 | 9,687.9 | 30,515.0 | សរុប | 4,422.0 | 4,221.0 | 3,422.0 | 12,065.0 | 6,560.6 | 5,623.5 | 6,265.9 | 18,450.0 |
| | | | | | រាជរដ្ឋាភិបាល | 284.8 | 273.8 | 234.8 | 793.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 4,137.3 | 3,947.3 | 3,187.3 | 11,271.8 | | | | |
| សរុប | 19,962.3 | 14,037.6 | 10,427.9 | 44,427.8 | សរុប | 13,401.7 | 8,414.1 | 4,162.0 | 25,977.8 | 6,560.6 | 5,623.5 | 6,265.9 | 18,450.0 |
| | | | | | រាជរដ្ឋាភិបាល | 584.8 | 473.8 | 264.8 | 1,323.3 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 12,816.9 | 7,940.4 | 3,897.3 | 24,654.5 | | | | |
| **4. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 84,530.8 | 88,757.4 | 93,195.2 | 266,483.4 | សរុប | 42,265.4 | 44,378.7 | 46,597.6 | 133,241.7 | 42,265.4 | 44,378.7 | 46,597.6 | 133,241.7 |
| | | | | | រាជរដ្ឋាភិបាល | 4,226.5 | 4,437.9 | 4,659.8 | 13,324.2 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 38,038.9 | 39,940.8 | 41,937.9 | 119,917.5 | | | | |
| សរុប | 84,530.8 | 88,757.4 | 93,195.2 | 266,483.4 | សរុប | 42,265.4 | 44,378.7 | 46,597.6 | 133,241.7 | 42,265.4 | 44,378.7 | 46,597.6 | 133,241.7 |
| | | | | | រាជរដ្ឋាភិបាល | 4,226.5 | 4,437.9 | 4,659.8 | 13,324.2 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 38,038.9 | 39,940.8 | 41,937.9 | 119,917.5 | | | | |

| ក្រសួង ស្ថាប័ន | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ | ប្រភព ហិរញ្ញប្បទាន | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ | ២០១៤ | ២០១៥ | ២០១៦ | សរុប ២០១៤-២០១៦ |
| **ទសវ័យសេដ្ឋកិច្ច** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 409,433.6 | 306,773.9 | 266,618.5 | 982,826.0 | សរុប | 359,571.6 | 256,914.3 | 219,763.7 | 836,249.6 | 49,862.0 | 49,859.6 | 46,854.7 | 146,576.4 |
| | | | | | រាជរដ្ឋាភិបាល | 86,807.0 | 46,904.1 | 36,632.6 | 170,343.6 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 272,764.6 | 210,010.2 | 183,131.2 | 665,906.0 | | | | |
| គម្រោងសម្រាប់អនុវត្ត ផយអជ | 154,802.1 | 279,317.7 | 416,719.8 | 850,839.7 | សរុប | 74,525.0 | 129,360.0 | 173,273.0 | 377,158.0 | 80,277.1 | 149,957.7 | 243,446.8 | 473,681.7 |
| | | | | | រាជរដ្ឋាភិបាល | 12,835.0 | 16,755.0 | 15,695.0 | 45,285.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 61,690.0 | 112,605.0 | 157,578.0 | 331,873.0 | | | | |
| សរុប | 564,235.8 | 586,091.6 | 683,338.3 | 1,833,665.7 | សរុប | 434,096.6 | 386,274.3 | 393,036.7 | 1,213,407.6 | 130,139.2 | 199,817.3 | 290,301.6 | 620,258.1 |
| | | | | | រាជរដ្ឋាភិបាល | 99,642.0 | 63,659.1 | 52,327.6 | 215,628.6 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 334,454.6 | 322,615.2 | 340,709.2 | 997,779.0 | | | | |
| **5. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 24,256.0 | 21,633.8 | 14,898.8 | 60,788.5 | សរុប | 24,256.0 | 20,633.8 | 14,898.8 | 59,788.5 | | 1,000.0 | | 1,000.0 |
